**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៣ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតក្រុមវិភាគព័ត៌មាន

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**ស ម្រេ ច**

**មាត្រា ១.-**

ត្រូវបានបង្កើត ក្រុមវិភាគព័ត៌មាន ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្រុមវិភាគព័ត៌មានត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាទីប្រឹក្សាផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អមដោយអនុប្រធាន និងសមាជិកដែលមានជំនាញ និងបច្ចេកទេសច្បាស់លាស់មួយចំនួន ។

សមាសភាពនៃក្រុមវិភាគព័ត៌មាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

ក្រុមវិភាគព័ត៌មាន មានតួនាទី និងភារកិច្ចដូចខាងក្រោមនេះ :

- តាមដាន ជ្រើសរើសព័ត៌មានសំខាន់ៗទាក់ទងនឹងព្រឹត្តិការណ៍ពិភពលោក ពិសេសព្រឹត្តិការណ៍ក្នុងតំបន់ ដែលមានឥទ្ធិពលដល់ការពិចារណាក្នុងការធ្វើសេចក្តីសម្រេចខាងនយោបាយក្រៅប្រទេសរបស់រាជរដ្ឋាភិបាល
- ផ្តល់នូវទស្សនៈ ការវិភាគ និងធ្វើសំយោគអំពីព្រឹត្តិការណ៍ទាំងនោះ ដើម្បីបម្រើគោលដៅខាងលើនេះ
- ធ្វើការស្រាវជ្រាវ និងពន្យល់អត្ថន័យប្រវត្តិសាស្ត្រ ភូមិសាស្ត្រ-នយោបាយ និងយុទ្ធសាស្ត្រនៃបញ្ហា ឬព្រឹត្តិការណ៍លេចធ្លោនានាក្នុងលោក
- តាមដានអំពីការសរសេរ ការយល់ឃើញ ការវាយតម្លៃអំពីកម្ពុជាលើសារព័ត៌មានអន្តរជាតិ និងក្នុងមជ្ឈដ្ឋានការទូត
- ទុកដាក់ រៀបចំ និងគ្រប់គ្រងឯកសារតាមប្រព័ន្ធកុំព្យូទ័រ និងតាក់តែងជំនួយស្មារតីជូនសម្តេចប្រមុខរាជរដ្ឋាភិបាលតាមការចាំបាច់
- ទាក់ទងការងារជាមួយគ្រប់ក្រសួងស្ថាប័ន រាប់ទាំងស្ថាប័នបរទេសផង ដើម្បីបុព្វហេតុស្រាវជ្រាវរបស់ខ្លួន
- បំពេញការងារផ្សេងទៀតតាមអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ក្រុមវិភាគព័ត៌មានត្រូវប្រើប្រាស់ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុរបស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ។

ក្រុមវិភាគព័ត៌មានមានសិទ្ធិប្រើប្រាស់ត្រារបស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ។

**មាត្រា ៥.-**

ក្រុមវិភាគព័ត៌មានមានកញ្ចប់ថវិកាសម្រាប់ដំណើរការការងារក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ